មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម
NATIONAL COMMERCIAL ARBITRATION CENTRE

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

លេខ: ០០៧/ម.ជ.ម./១៦

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំងក្រុមគ្រូបង្គោលរបស់ ម.ជ.ម.

## ប្រធានមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៨២ អនក្រ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា ៥២នៃអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម
- បានឃើញកំណត់ហេតុមហាសន្និបាតលើកទី២ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ស្តីពីលទ្ធផលបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាប្រតិបត្តិរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម។
- បានឃើញកំណត់ហេតុបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធាន និងហេរញ្ញិក ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៦របស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម។
- បានឃើញបទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤
- យោងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រតិបត្តិនាសម័យប្រជុំថ្ងៃទី២២ខែ មេសាឆ្នាំ២០១៦

## សម្រេច

**ប្រការ ១.-**

តែងតាំងសមាសភាពក្រុមគ្រូបង្គោលរបស់ ម.ជ.ម. ដូចខាងក្រោម៖

១. លោក ភិន សុវត្ថិ ជាប្រធានក្រុមគ្រូបង្គោល

២. លោក ខាន់ សិរីវុទ្ធី ជាអនុប្រធានក្រុមគ្រូបង្គោល

៣. លោកស្រី សេង វួចហ៊ិន ជាគ្រូបង្គោល

៤. លោក អ៊ុក សុភាព ជាគ្រូបង្គោល

៥. លោក ទេស ចំរើន ជាគ្រូបង្គោល

៦. លោក វង្ស មុនាថ ជាគ្រូបង្គោល

៧. លោកស្រី ខៀវ មាលី ជាគ្រូបង្គោល

៨. លោក ប៊ុន យូឌី ជាគ្រូបង្គោល

៩. លោក អ៊ិច វុធ្វី ជាគ្រូបង្គោល

**ប្រការ ២.-**

តួនាទី និងភារកិច្ចរបស់ក្រុមគ្រូបង្គោល មានដូចខាងក្រោម៖

- រៀបចំឯកសារសំរាប់បណ្តុះបណ្តាលដល់អ្នកដែលចង់ក្លាយជាគ្រូនៅ ម.ជ.ម.។
- ក្រុមគ្រូបង្គោល ត្រូវផ្តល់យោបល់របស់ខ្លួនស្របតាមសំណូមពររបស់ ក្រុមប្រឹក្សាប្រតិបត្តិពាក់ពន្ធ័នឹងគោលនយោបាយ ទាក់ទងនឹងការអប់រំ និងកម្មវិធីបណ្តុះបណ្តាល។
- ក្រុមគ្រូបង្គោល ត្រូវចូលរួមជួយបណ្តុះបណ្តាលក្នុងកម្មវិធីបណ្តុះបណ្តាលដល់ការបណ្តុះបណ្តាលដំបូង និងការបណ្តុះបណ្តាលបន្ត តាមការរៀបចំរបស់ ម.ជ.ម. ដោយការស្ម័គ្រចិត្ត។
- គ្រូបង្គោលអាចជាវាគ្មិនផ្លូវការនៅតាមកម្មវិធីនានា ដែលត្រូវបានចាត់តាំងដោយ ម.ជ.ម. ឬតាមការស្នើសុំពីមជ្ឈដ្ឋាននានាពាក់ព័ន្ធនឹងវិស័យមជ្ឈត្តការ។
- បំពេញតួនាទីផ្សេងៗទៀតតាមការស្នើសុំរបស់ក្រុមប្រឹក្សាប្រតិបត្តិ។

**ប្រការ ៣.-**

ការបំពេញតួនាទីជាសមាជិកក្រុមគ្រូបង្គោល អាចត្រូវបានគិតតម្លៃតាមការសម្រេចពីក្រុមប្រឹក្សាប្រតិបត្តិ សម្រាប់គ្រូបង្គោលណា ដែលស្ម័គ្រចិត្តចូលរួមផ្តល់ការបណ្តុះបណ្តាលដែលរៀបចំដោយ ម.ជ.ម. ។

សមាជិកក្រុមគ្រូបង្គោល ដែលមានបំណងលាឈប់ពីក្រុមគ្រូបង្គោល ត្រូវបញ្ជូនលិខិតលាឈប់ ទៅក្រុមប្រឹក្សាប្រតិបត្តិ។

**ប្រការ ៤.-**

ប្រធាន ម.ជ.ម. ឬបុគ្គលដែលចាត់តាំងដោយប្រធាន ម.ជ.ម. ឬប្រធានក្រុមគ្រូបង្គោលជាប្រធានអង្គប្រជុំ ជាអ្នកកោះប្រជុំ ដឹកនាំអង្គប្រជុំ និងសម្របសម្រួលអង្គប្រជុំ។ អនុប្រធានក្រុមគ្រូបង្គោលជួយការងារប្រធានក្រុមគ្រូបង្គោល តាមការចាត់តាំង។ ក្នុងករណីប្រធានក្រុមគ្រូបង្គោលអវត្តមាន អនុប្រធាន ត្រូវជំនួសប្រធាន។ ប្រធានអង្គប្រជុំ អាចចាត់តាំងសមាជិកណាម្នាក់ឲ្យធ្វើជាលេខាកត់ត្រា។ តាមការចាំបាច់ លេខាធិការដ្ឋានអាចផ្តល់បុគ្គលិករបស់ខ្លួនសម្រាប់ជួយក្រុមគ្រូបង្គោល ប្រសិនបើមានការស្នើសុំ។

**ប្រការ ៥**.-

សេចក្ដីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្ដីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦**.-

សាមីខ្លួន អគ្គលេខាធិការ និងហេរញ្ញិក ត្រូវអនុវត្តសេចក្ដីសម្រេចនេះតាមមុខការរៀងៗខ្លួន។

*រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦*

**ប្រ ធា ន**

មជ្ឈត្តការ រស់ មុជិន្ទ:

**<u>ចម្លងជូន:</u>**

- សមាជិកក្រុមប្រឹក្សាប្រតិបត្តិ
  "ដើម្បីជ្រាប"
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ



Tel : (+855) 23 21 32 62